# **លិខិតបញ្ជាក់ពីសិទ្ធិទទួលបានជំនួយថ្លៃឈ្នួលសម្រាប់**
## កម្មវិធីជំនួយថ្លៃឈ្នួលផ្ទះដែលទទួលបានការឧបត្ថម្ភពេលមានអាសន្ន (SHERA)

### ផ្នែកទី 1៖ ព័ត៌មានអំពីគ្រួសារដែលទទួលបានជំនួយ និងសិទ្ធិទទួលបានជំនួយ

| ឈ្មោះអចលនទ្រព្យ | អាសយដ្ឋានអគារ | លេខបន្ទប់របស់អ្នកជួល |
|---|---|---|
| | | |
| ទីក្រុង/ទីប្រជុំជន | ហ្ស៊ីបកូដ | |
| | | |
| ឈ្មោះអ្នកជួល (មេគ្រួសារ) | ថ្ងៃខែឆ្នាំកំណើតរបស់អ្នកជួល (ខែ/ថ្ងៃ/ឆ្នាំ) | លេខ SSN បួនខ្ទង់ចុងក្រោយ* *ប្រសិនបើអ្នកមាន។ អ្នកមិនចាំបាច់ត្រូវការលេខ SSN ដើម្បីដាក់ពាក្យសុំជំនួយនោះទេ។* |
| | / / | |
| អ៊ីមែល | លេខទូរសព្ទ | |
| | ( ) | XXXX – XX – |

**ព័ត៌មានអំពីមេគ្រួសារ៖**

- **តើអ្នកពិបាកយល់ភាសាអង់គ្លេសមែនទេ?**
  - ❒ បាទ/ចាស
  - ❒ ទេ
- **តើភាសាអង់គ្លេសជាភាសាចម្បងរបស់អ្នកមែនទេ?**
  - ❒ បាទ/ចាស
  - ❒ ទេ ភាសាដែលខ្ញុំចូលចិត្តគឺ៖
- **តើអ្នកមានសញ្ជាតិអ្វី?**
  - ❒ ជនជាតិដើមអាមេរិកាំងឥណ្ឌា ឬអាឡាស្កា
  - ❒ អ្នកកោះអាស៊ី ឬប៉ាស៊ីហ្វិក
  - ❒ ជនជាតិអាមេរិកស្បែកខ្មៅ ឬអាហ្វ្រិកអាមេរិក
  - ❒ ជនជាតិស្បែកស
  - ❒ ផ្សេងទៀត
  - ❒ សុំមិនឆ្លើយ
- **តើអ្នកជាជនជាតិអេស្ប៉ាញ ជនជាតិអាមេរិកឡាទីន**
  - ❒ បាទ/ចាស
  - ❒ ទេ
  - ❒ សុំមិនឆ្លើយ
- **តើអ្នកមានភេទអ្វី?**
  - ❒ ស្រី
  - ❒ ប្រុស
  - ❒ មិនមែនទាំងប្រុស ឬស្រី
  - ❒ សុំមិនឆ្លើយ

- **បន្ថែមពីលើការទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីស្ថានភាពពាក្យសុំរបស់អ្នក តើអ្នកចង់ទទួលបានព័ត៌មានថ្មីៗតាមអ៊ីមែល ឬតាមរយៈសារជាអក្សរដែរឬទេ?**
  - ❒ បាទ/ចាស តាមរយៈលេខទូរសព្ទដែលខ្ញុំបានផ្តល់ឱ្យ
  - ❒ បាទ/ចាស តាមរយៈអ៊ីមែលដែលខ្ញុំបានផ្តល់ឱ្យ
  - ❒ ទេ សូមផ្ញើសេចក្តីជូនដំណឹងមកខ្ញុំតាមរយៈសំបុត្រប្រៃសណីយ៍តែប៉ុណ្ណោះ

- **អ្នកចុះហត្ថលេខានៅខាងក្រោមនេះបញ្ជាក់ថា (គូសធីកទាំងអស់ដែលពាក់ព័ន្ធ)៖**
  - ❒ ខ្ញុំត្រូវបានចុះបញ្ជីជាអ្នកជួល ឬអ្នកជួលបន្តលើកិច្ចសន្យាជួលជាលាយលក្ខណ៍អក្សរសម្រាប់បន្ទប់នេះ
  - ❒ បន្ទប់នេះគឺជាទីលំនៅចម្បងរបស់ខ្ញុំ (កន្លែងដែលខ្ញុំរស់នៅស្ទើរតែគ្រប់ពេល)

នៅពេលណាមួយ ចាប់តាំងពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2020 ដោយទទួលរងដោយផ្ទាល់ ឬដោយប្រយោលពីការផ្ទុះជំងឺ COVID-19 ខ្ញុំ ឬបុគ្គលផ្សេងទៀតនៅក្នុងគ្រួសាររបស់ខ្ញុំ៖

- ❒ មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានអត្ថប្រយោជន៍សម្រាប់ភាពគ្មានការងារធ្វើ
- ❒ បាត់បង់ប្រាក់ចំណូល
- ❒ ការចំណាយមានការកើនឡើង និង/ឬ
- ❒ មានការលំបាកផ្នែកហិរញ្ញវត្ថុផ្សេងទៀត។ ពន្យល់ដោយសង្ខេប៖ ____________________

❒ ខ្ញុំ ឬបុគ្គលផ្សេងទៀតនៅក្នុងគ្រួសាររបស់ខ្ញុំគ្មានការងារធ្វើអស់រយៈពេលយ៉ាងហោចណាស់ 90 ថ្ងៃចុងក្រោយ

## ផ្នែកទី 2៖ ការបញ្ជាក់ និងការយល់ព្រមពីគ្រួសារ

- ខ្ញុំជំពាក់ថ្លៃជួលដែលបានដល់កំណត់ត្រូវបង់គិតចាប់តាំងពីខែមេសា ឆ្នាំ 2020 ឬរយៈពេលក្រោយពីនេះ។

- ខ្ញុំសូមបញ្ជាក់ស្របតាមការពិន័យលើសក្ខីភាពទុច្ចរិតថា រាល់ព័ត៌មាន និងចម្លើយដែលបានឆ្លើយតប នឹងសំណួរទាំងនេះគឺពិត និងពេញលេញទៅតាមចំណេះដឹងដែលខ្ញុំមាន។

- ខ្ញុំសូមបញ្ជាក់ថាប្រសិនបើខ្ញុំទទួលបានថវិកាពីប្រភពផ្សេងទៀតសម្រាប់ថ្លៃជួលដូចគ្នាដែលបានបង់ដោយកម្មវិធីជំនួយថ្លៃជួលផ្ទះដែលទទួលបានការឧបត្ថម្ភពេលមានអាសន្ន (“SHERA”) ខ្ញុំនឹងជូនដំណឹងដល់ម្ចាស់ផ្ទះខ្ញុំភ្លាមៗ និងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីធានាថាថវិកាទាំងនោះត្រូវបានប្រគល់ទៅឱ្យប្រភពដើមវិញ។

- ខ្ញុំយល់ព្រមថាម្ចាស់ផ្ទះរបស់ខ្ញុំ ឬបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពីម្ចាស់ផ្ទះរបស់ខ្ញុំអាចនឹងដាក់ពាក្យសុំកម្មវិធី SHERA ដើម្បីឱ្យខ្ញុំបង់បំណុលថ្លៃជួលផ្ទះដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជំពាក់គិតត្រឹមថ្ងៃនេះ និងសម្រាប់បំណុលជួលផ្ទះដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលអាចនឹងជំពាក់នាពេលអនាគត។

- ខ្ញុំយល់ព្រម និងយល់ស្របថារាល់ព័ត៌មានដែលត្រូវការ ដើម្បីដំណើរការពាក្យសុំជំនួយនេះអាចត្រូវបានចែករំលែកជាមួយម្ចាស់ផ្ទះ និងអ្នកគ្រប់គ្រង អចលនទ្រព្យរបស់ខ្ញុំរួមមាន Commonwealth of Massachusetts Department of Housing and Community Development (“DHCD”, Massachusetts Housing Finance Agency (“MassHousing”) ឬ Massachusetts Housing Partnership (“MHP”), ក៏ដូចជាបុគ្គល ឬទីភ្នាក់ងារផ្សេងទៀតដែលមានកិច្ចសន្យាជាមួយ DHCD, MassHousing ឬ MHP ក្នុងការជួយដំណើរការពាក្យសុំជំនួយនេះផងដែរ។

- ខ្ញុំដឹងហើយថាប្រសិនបើ MassHousing ឬ MHP (ឬភ្នាក់ងាររបស់ខ្លួន) ទីភ្នាក់ងារផ្តល់ជំនួយសហព័ន្ធ ឬទីភ្នាក់ងារសវនកម្មរកឃើញថាខ្ញុំបានទទួលប្រាក់មិនត្រឹមត្រូវដោយសារតែខ្ញុំបានផ្តល់ព័ត៌មានមិនពិត ឬផ្តល់អំណះអំណាងមិនត្រឹមត្រូវនៅក្នុងលិខិតនេះ ឬពាក្យសុំរបស់ខ្ញុំ ខ្ញុំអាចនឹងត្រូវសងជំនួយខ្លះ ឬទាំងអស់ដែលផ្តល់ដោយ DHCD, MassHousing, MHP ឬម្ចាស់ផ្ទះរបស់ខ្ញុំ។

- ខ្ញុំដឹងហើយថាវាជាបទឧក្រិដ្ឋដែលកុហក ឬផ្តល់ព័ត៌មានមិនពិតនៅក្នុងលិខិតនេះ ឬពាក្យសុំរបស់ខ្ញុំ។ ខ្ញុំក៏ដឹងថាពាក្យសុំរបស់ខ្ញុំអាចត្រូវបានបដិសេធ ប្រសិនបើខ្ញុំបានធ្វើផ្តល់សេចក្តីថ្លែងការណ៍មិនពិត ឬមិនត្រឹមត្រូវ។

*ការវាយបញ្ចូលឈ្មោះរបស់អ្នកក្នុងកន្លែងបញ្ចូលហត្ថលេខាខាងក្រោមមានន័យថា អ្នកកំពុងចុះហត្ថលេខាលើឯកសារនេះតាមប្រព័ន្ធអេឡិចត្រូនិក។ ហត្ថលេខាអេឡិចត្រូនិកមានអត្ថន័យ សុពលភាព និងប្រសិទ្ធភាពដូចគ្នានឹងហត្ថលេខាសរសេរដោយដៃដែរ។*

| ____________________ | ____________________ |
|---|---|
| **ហត្ថលេខារបស់មេគ្រួសារ** | **កាលបរិច្ឆេទ** |